# ចំណេះចំណានខាងគោលលទ្ធិ ៖ ការវាយតម្លៃទី ១—សៀវភៅមគ្គុទេសក៍ការសិក្សា

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ ថ្នាក់សិក្ខាសាលា

## ទន្ទេញចាំសេចក្តីយោង និងឃ្លាបទគម្ពីរគន្លឹះ

សូមស្គាល់វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិ និងឃ្លាបទគម្ពីរគន្លឹះ ។ អ្នកប្រហែលជាចង់ទាញយក និងប្រើកម្មវិធីឧបករណ៍ចល័តចំណេះ ចំណានខាងគោលលទ្ធិ ដើម្បីជួយអ្នកឲ្យរំឭកឡើងវិញ ។

ម៉ាថាយ ៥:១៤–១៦ ។ « ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោក » ។

ម៉ាថាយ ១១:២៨–៣០ ។ « អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក » ។

ម៉ាថាយ ១៦:១៥–១៩ ។ ព្រះយេស៊ូវបានមានបន្ទូលថា « ខ្ញុំនឹងឲ្យកូនសោនៃនគរស្ថានសួគ៌ដល់អ្នក » ។

ម៉ាថាយ ២២:៣៦–៣៩ ។ « ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯង ។... ត្រូវឲ្យស្រឡាញ់អ្នកជិតខាង » ។

លូកា ២:១០–១២ ។ « ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » ។

លូកា ២២:១៩–២០ ។ ព្រះយេស៊ូវគ្រីស្ទបានបង្គាប់ថា ចូរទទួលទានសាក្រាម៉ង់ « ដើម្បីរំឭកពីខ្ញុំចុះ » ។

លូកា ២៤:៣៦–៣៩ ។ « ដ្បិតខ្មោចគ្មានសាច់ ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ » ។

យ៉ូហាន ៣:៥ ។ « បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ » ។

យ៉ូហាន ៣:១៦ ។ « ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ » ។

យ៉ូហាន ៧:១៧ ។ « បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះ » ។

យ៉ូហាន ១៧:៣ ។ « នេះជាជីវិតដ៏អស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ » ។

## អនុវត្តគោលលទ្ធិទៅនឹង ស្ថានភាពជីវិតជាក់ស្តែង

- សូមប្រើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិមួយ ឬច្រើនដើម្បីឆ្លើយតបនឹងនរណាម្នាក់ដែលសួរថា « តើព្រះគម្ពីរសញ្ញាថ្មីបង្រៀនអ្វីខ្លះ អំពីការទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនថា គោលលទ្ធិដែលបានបង្រៀននៅក្នុងសាសនាចក្រគឺមកពីព្រះ ? »
- ប្រសិនបើអ្នកចង់បង្រៀននរណាម្នាក់អំពីសេចក្តីស្រឡាញ់របស់ព្រះចំពោះពួកគេ តើវគ្គបទគម្ពីរចំណេះ ចំណានខាងគោលលទ្ធិក្នុងព្រះគម្ពីរសញ្ញាថ្មីមួយណាដែលអ្នកអាចប្រើ ? តើអ្នកអាចប្រើវគ្គបទគម្ពីរទាំងនេះដើម្បីពន្យល់អំពីសេចក្តីស្រឡាញ់របស់ព្រះដោយរបៀបណា ?

សូមត្រៀមខ្លួនដើម្បីចែកចាយវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិណាដែលមានឥទ្ធិពលដល់អ្នកខ្លាំងបំផុត ។ តើវគ្គបទគម្ពីរនោះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

## គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ

សូមរំឭកកថាខណ្ឌទី ៥–១២ នៅក្នុងផ្នែក « ការទទួលបានចំណេះដឹងខាងវិញ្ញាណ » នៃ *ឯកសារគោលនៃចំណេះចំណានខាងគោលលទ្ធិ* ( ឆ្នាំ ២០២២ ) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែ នៃ *New Testament Doctrinal Mastery: Assessment 9—Study Guide* ។ Cambodian ។ PD60012661 258. Printed in the United States of America.